# សុន្ទរកថា

# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការគោលនយោបាយ និង ហិរញ្ញវត្ថុ

## ថ្លែងក្នុង

## ពិធីប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ «កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដ-ប្រជាខ្ពស់ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា»

*រាជធានីភ្នំពេញ, ថ្ងៃ អង្គារ ២ កើត ខែ មាឃ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២៥៦៩*
*ត្រូវនឹងថ្ងៃទី ២០ ខែ មករា គ.ស. ២០២៦, សណ្ឋាគារសុខាភ្នំពេញ*

***** + *****

- *ឯកឧត្តមរដ្ឋមន្ត្រី;*
- *ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័ន, តំណាងអង្គទូត និង តំណាងដៃគូអភិវឌ្ឍ;*
- *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និង អន្តរ-ជាតិ, សមាជិក-សមាជិកានៃអង្គពិធី, ជាទីមេត្រី!*

ថ្ងៃនេះ, ខ្ញុំពិតជាមានកិត្តិយសដ៏ឧត្តុង្គឧត្តម និង សេចក្តីសោមនស្សក្រៃលែង ដោយទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត ពីសំណាក់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, ចូលរួមជាអធិបតី ក្នុងពិធីប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹង**

**ភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដ-ប្រជាខ្ពស់ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា»**, តទៅនេះ, ខ្ញុំសូមហៅកាត់ថា «**កម្មវិធី**» ។ ជាសារជាតិ, **កម្មវិធី** នេះ គឺជាឯកសារបំពេញបន្ថែមលើ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**, ដែលក្នុងនោះ វិធានការគោលនយោបាយជាច្រើន របស់រាជរដ្ឋាភិបាល ត្រូវបានយកមករៀបចំ, សម្រួល និង សម្រួច ឲ្យកាន់តែចំទិសដៅ និង កាន់តែសមស្រប ទៅនឹងបរិការណ៍សង្គម-សេដ្ឋកិច្ច កម្ពុជា, តំបន់ និង សកល, ដែលកំពុងវិវត្តយ៉ាងរហ័ស និង ពិបាកប៉ាន់ស្មាន ។

ចំណងជើងនៃឯកសារ ដែលត្រូវបានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នាថ្ងៃនេះ ពិតជាសមស្រប ទៅនឹងកាលៈទេសៈបច្ចុប្បន្ន ដែលកម្ពុជា និង ពិភពលោក កំពុងជួបប្រឈម, នោះគឺ ភាពមិនប្រាកដប្រជាខ្ពស់នៃសណ្តាប់ធ្នាប់សកល និង តំបន់, ទាំងលើទិដ្ឋភាពភូមិសាស្ត្រនយោបាយ និង ភូមិសាស្ត្រសេដ្ឋកិច្ច ។ ការណ៍នេះ កំពុងបង្កឲ្យមានបញ្ហាប្រឈម និង ហានិភ័យផ្នែកសន្តិសុខ, ដែលជាយថាហេតុ អាចបំផ្លាញសន្តិភាពដ៏ផុយស្រួយ និង អាចបង្កផលប៉ះពាល់អវិជ្ជមាន ដល់និរន្តរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ជារួម, ពិសេស សម្រាប់ប្រទេសកំពុងអភិវឌ្ឍ, ដែលមានមូលដ្ឋានសេដ្ឋកិច្ច និង អភិបាលកិច្ច មិនទាន់រឹងមាំគ្រប់គ្រាន់នៅឡើយ និង ពឹងផ្អែកខ្លាំង លើរបៀបរបបនៃអភិបាលកិច្ច និង សណ្តាប់ធ្នាប់នៃការដឹកនាំសកល, សាកលភាវូបនីយកម្ម, សេរីភាវូបនីយកម្ម និង ពហុភាគីនិយម ដែលផ្អែកលើវិធាន និង ច្បាប់អន្តរជាតិ ជាចម្បង ។

ប្រឈមមុខនឹងស្ថានភាពបែបនេះ, ថ្វីត្បិតតែជាប្រទេសតូច មិនសូវមានជម្រើសច្រើន, ប៉ុន្តែ កម្ពុជាមិនប្រកាន់យកនូវ អភិក្រមបែប «**ប្រតិកម្ម**» (Reactive) ដោយបាត់ម្ចាស់ការនោះទេ ។ ផ្ទុយទៅវិញ, យើងបានតាំងចិត្តខិតខំពង្រឹងភាពធន់របស់ខ្លួន ដែលអាចផ្តល់នូវលំហសមស្រប សម្រាប់អនុញ្ញាតឲ្យយើង អាចធ្វើសកម្មភាព ក្នុងអភិក្រមបែប «**បុរេសកម្ម**» (Proactive) ប្រកបដោយភាពបត់បែន (Flexible) និង បរិវត្តកម្ម (Transformative) ស្របទៅនឹងតថភាព និង បរិបទនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅកម្ពុជា ក៏ដូចជា ក្នុងតំបន់ និង លើសកលលោក ដែលបន្តផ្លាស់ប្តូរ និង ប្រែប្រួលឥតឈប់ឈរ, ព្រមទាំង ឆ្លើយតបទៅនឹងទស្សនវិស័យរយៈពេលវែងរបស់យើង ។ ក្នុង

ន័យនេះ, ការរៀបចំដាក់ចេញ នូវ **កម្មវិធី** ដោយរួមបញ្ចូលនូវផែនការសកម្មភាព និង វិធានការដាក់លាក់, ទាំងសម្រាប់រយៈពេលខ្លី, មធ្យម និង វែង, គួបផ្សំជាមួយនឹងយន្តការតាមដាន និង ត្រួតពិនិត្យច្បាស់លាស់, ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានានូវប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព នៃការអនុវត្តគោលនយោបាយ និង ផែនការយុទ្ធសាស្ត្រសំខាន់ទាំងឡាយ របស់រាជរដ្ឋាភិបាល សំដៅពង្រឹងអភិបាលកិច្ច, ជំរុញកំណើនសេដ្ឋកិច្ច និង ធានានិរន្តរភាពនៃការអភិវឌ្ឍ ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

ដូច **ឯកឧត្តមបណ្ឌិតសភាចារ្យ ផាន់ ផល្លា**, រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអគ្គលេខាធិការនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានគូសរំលេច ក្នុងរបាយការណ៍ នៅមុននេះបន្តិច, **កម្មវិធី** នេះ ត្រូវបានរៀបចំឡើង ទន្ទឹមគ្នានឹងការបន្តប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមចម្បងនានា ចំពោះមុខ, ជាអាទិ៍៖ ពន្ធគយបដិការ និង ផលប៉ះពាល់ពីសង្គ្រាមឈ្លានពាន មកលើការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ជាមួយនឹងភាពមិនប្រាកដប្រជាខ្ពស់ជាច្រើនទៀត ។ល។ ក្នុងន័យនេះ, ការដាក់ឲ្យអនុវត្តនូវ **កម្មវិធី** នេះ គឺជាសក្ខីភាពនៃការខិតខំដោះស្រាយបញ្ហាប្រឈមចំពោះមុខ ដើម្បីរក្សាលំនឹងជីវភាពប្រជាពលរដ្ឋ និង បន្តជំរុញកំណើនសេដ្ឋកិច្ច ផង និង ជាការឆ្លុះបញ្ចាំងឲ្យឃើញច្បាស់ ពីគោលជំហរដ៏មុឹងម៉ាត់ និង ឆន្ទៈដ៏មោះមុត របស់រាជរដ្ឋាភិបាល ក្នុងការថែរក្សាសន្តិភាព និង ការការពារអធិបតេយ្យ ជាតិ និង បូរណភាពទឹកដី ផង ដោយឈរលើអភិក្រមនៃការប្រែក្លាយបញ្ហាប្រឈម ឲ្យទៅជាកាលានុវត្តភាព តាមរយៈ ការជំរុញការអភិវឌ្ឍសមត្ថភាព និង ការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម, ការពង្រឹងឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា, ការពង្រឹងលទ្ធភាពលើកកម្ពស់ខ្សែច្រវាក់ផលិតកម្មក្នុងស្រុក សំដៅជំរុញការតភ្ជាប់ទៅនឹងខ្សែច្រវាក់ផ្គត់ផ្គង់ ក្នុងតំបន់ និង លើសកលលោក, ការចាប់យកសកម្មភាពផលិតកម្មដែលបង្កើតតម្លៃបន្ថែមខ្ពស់, ការបង្កើតការងារកាន់តែច្រើន សម្រាប់កម្លាំងពលកម្ម ដែលមានជំនាញមធ្យម និង ខ្ពស់, ការពង្រីកមូលដ្ឋានសេដ្ឋកិច្ចជាតិ ឲ្យកាន់តែទូលំទូលាយ ។ល។ ការណ៍នេះ នឹងរួមចំណែកដ៏សំខាន់ ដល់ការជំរុញកំណើនសេដ្ឋកិច្ច និង ការពង្រឹងឯករាជ្យភាពនៃ

សេដ្ឋកិច្ចជាតិ, ខណៈដែលស្មារតីស្នេហាជាតិ និង ចលនារួបរួមជាតិ កាន់តែមានសន្ទុះខ្លាំងឡើង, ដែលជំរុញដល់ការលើកស្ទួយ និង ការឲ្យតម្លៃខ្ពស់ ដល់ផលិតផលក្នុងស្រុក ។

ក្នុងន័យនេះ, ការដាក់ចេញ នូវ **កម្មវិធី** នេះ ក៏បានបង្ហាញច្បាស់ផងដែរ អំពីការប្តេជ្ញាចិត្ត និង ឆន្ទៈមោះមុតឥតរាថយ របស់រាជរដ្ឋាភិបាល ក្នុងការបន្តពង្រឹងភាពធន់នៃសេដ្ឋកិច្ច ក៏ដូចជា ភាពធន់នៃសង្គមកម្ពុជា ។ ក្នុងស្មារតីនេះ, ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ ចំពោះអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង ដៃគូអភិវឌ្ឍនានា, ជាពិសេស CAPRED, ដែលបានចូលរួមផ្តល់ធាតុចូល និង ផ្តល់កិច្ចសហការល្អ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំ **កម្មវិធី** នេះឡើង រហូតសម្រេចបានជោគជ័យ និង ត្រូវបានដាក់ឲ្យអនុវត្តជាផ្លូវការ នាឱកាសនេះ ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

ក្នុងរយៈពេលជិត ៣ ទសវត្សរ៍ ចុងក្រោយនេះ, តាមរយៈការខិតខំឥតស្រាកស្រាន្ត និង ការកែទម្រង់មុតស្រួចឥតងាករេ លើគ្រប់វិស័យ របស់រាជរដ្ឋាភិបាល, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និង ជវភាព របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី** និង បច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភា**, និង ការបន្តវេនដឹកនាំ ប្រកបដោយថាមភាព របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់នីតិកាលទី ៧ នេះ នៃរដ្ឋសភា, កម្ពុជា បន្តសម្រេចបាននូវសមិទ្ធផលដ៏ធំធេងជាច្រើន និង បានផ្លាស់ប្តូរមុខមាត់ គួរជាទីមោទនៈ ដោយរក្សាបានយ៉ាងគត់មត់ នូវស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម, សន្តិសុខ, សុវត្ថិភាព, ព្រមទាំង ធានាបានយ៉ាងរឹងមាំនូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ។ បន្ថែមលើនេះ, សេដ្ឋកិច្ចកម្ពុជា បានស្ទុះងើបឡើងវិញយ៉ាងរហ័ស និង បន្តឈរលើមាគ៌ានៃកំណើនដ៏រឹងមាំ បន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ ជាសកល ទោះបីជាត្រូវបន្តពុះពារជម្នះ នូវបញ្ហាប្រឈម និង ភាពមិនប្រាកដប្រជាខ្ពស់ នៃស្ថានភាព តំបន់ និង សកល ដោយសារការបន្តប្រឈមមុខខាងភូមិសាស្ត្រនយោបាយ កាន់តែស្រួចស្រាល់; ការបែកខ្ញែកនៃសេដ្ឋកិច្ចសកល ដែលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការ និង ពាណិជ្ជកម្មអន្តរជាតិ; ការងើបមកវិញនៃនិន្នាការឯកតោភាគី-

និយម; ភាពមិនច្បាស់លាស់នៃទស្សនវិស័យកំណើនសេដ្ឋកិច្ច នៃបណ្តាប្រទេស និង តំបន់ ជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា, ការប្រែប្រួលអាកាសធាតុ ។ល។

ក្នុងដំណាក់កាលថ្មីនៃការបន្តខិតខំអភិវឌ្ឍប្រទេស, ចាប់តាំងពីដើមនីតិកាលទី ៧ នេះ នៃរដ្ឋសភា, រាជរដ្ឋាភិបាល បានដាក់ចេញ និង កំពុង ជំរុញអនុវត្ត នូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, ទន្ទឹមគ្នានឹង **កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦** និង **វិធានការគន្លឹះ ចំនួន ៥**, សំដៅខិតខំជម្នះឲ្យបាន នូវបញ្ហាប្រឈម និង សម្របខ្លួនទៅនឹងការប្រែប្រួលនៃសភាពការណ៍ ដែលកើតឡើងជាបន្តបន្ទាប់ និង ជំណាលៗគ្នា ដោយតម្រូវឲ្យរាជរដ្ឋាភិបាល ចាត់វិធានអន្តរាគមន៍ ឲ្យបានទាន់ពេល និង ចំទិសដៅ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពខ្ពស់ ។ ជាលទ្ធផល, ទោះបីត្រូវប្រឈមនឹងភាពមិនប្រាកដប្រជាកាន់តែស្រួចស្រាល់ ក្នុងបរិការណ៍សកល ក៏ដូចជាត្រូវប្រឈមនឹងការរំលោភ លើអធិបតេយ្យជាតិ និង បូរណភាពទឹកដី យ៉ាងណាក្តី, ក៏សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថា អាចនឹងសម្រេចបានកំណើន ក្នុងរង្វង់ប្រមាណ ៥,២% ក្នុងឆ្នាំ ២០២៥ និង ប្រមាណ ៥% សម្រាប់ឆ្នាំ ២០២៦ នេះ ។

ទន្ទឹមនេះ, កិច្ចខិតខំឥតរាថយ និង ឆន្ទៈមោះមុត របស់រាជរដ្ឋាភិបាល, សំដៅកែលម្អបរិយាកាសសម្រាប់ធុរកិច្ច និង ការវិនិយោគ, បានជំរុញឲ្យការវិនិយោគផ្ទាល់ពីក្រៅប្រទេស បន្តកើនខ្ពស់ គួរជាទីមោទនៈ ។ ជាក់ស្តែង, ផ្អែកតាមទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ការចុះបញ្ជីគម្រោងវិនិយោគពីបរទេស ក្នុងឆ្នាំ ២០២៥ កន្លងទៅ មានទំហំទុនសរុបប្រមាណ **១០ ប៊ីលានដុល្លារអាមេរិក**, មានកំណើន ៤៥% បើធៀបនឹងឆ្នាំ ២០២៤ ។ ជាមួយគ្នា, ក្នុងវិស័យពាណិជ្ជកម្មក្រៅប្រទេស, ការនាំចេញរបស់កម្ពុជា ក្នុងឆ្នាំ ២០២៥ ក៏បន្តរក្សាបាននូវចលនការកំណើនល្អ គួរឲ្យកត់សម្គាល់ ។ ជាក់ស្តែង, ការនាំចេញសរុប ក្នុងឆ្នាំ ២០២៥ បានកើនប្រមាណជាង ១៧%, បើធៀបនឹងឆ្នាំ ២០២៤ ។ ចំពោះវំហូរភ្ញៀវទេសចរណ៍, ការធ្វើដំណើរ និង កញ្ចប់ទេសចរណ៍ទីផ្សារឆ្ងាយ របស់ទេសចរបរទេស មកកាន់កម្ពុជា ក៏នៅដំណើរការជាធម្មតា និង មាននិន្នាការកើនផងដែរ តួយ៉ាងដូចជា ទេសចរ ពីអឺរ៉ុប, អូស្ត្រាលី និង ឥណ្ឌា ។

ការសម្រេចបាននូវលទ្ធផលដ៏ល្អខាងលើ បានបង្ហាញច្បាស់ថា **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** នៅតែត្រឹមត្រូវ, ចាំបាច់ និង សមស្រប, ប៉ុន្តែ គប្បី

ត្រូវបានសម្រួចបន្ថែម និង អនុវត្ត ប្រកបដោយភាពបត់បែន ទៅតាមនិន្នាការ និង បរិការណ៍នៃការប្រែប្រួលថ្មី ។ ជាទិសដៅទៅមុខ, រាជរដ្ឋាភិបាល បានកំណត់គោលដៅ **«រក្សាឲ្យបាននូវចលនការកំណើន និង ឈានទៅសម្រេចអត្រាកំណើនខ្ពស់ ក្នុងករណីស្ថានភាពសេដ្ឋកិច្ច សកលមានភាពប្រសើរឡើងវិញ»** ដោយប្រកាន់យកអភិក្រម ចំនួន ២ ទន្ទឹមគ្នា, ពោលគឺ៖ **ទី១.** ពុះពារដោះស្រាយបញ្ហាប្រឈមចំពោះមុខ, និង **ទី២.** គិតគូររៀបចំ និង ដាក់ចេញ នូវវិធានការគោលនយោបាយគាំទ្រកំណើន, ជាពិសេស សម្រាប់វិស័យជាចន្ទល់នៃកំណើន ដែលមិនទាន់ងើបឡើងវិញបានពេញលេញនៅឡើយ រួមមាន៖ វិស័យទេសចរណ៍ និង វិស័យសំណង់ និង អចលនទ្រព្យ ជាដើម ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាល បានសម្រេចដាក់ចេញនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា»** នេះ ជាមួយនឹងបេសកកម្ម៖ **«អនុវត្តរបៀបវារៈគោលនយោបាយជំរុញកំណើនសេដ្ឋកិច្ច ដូចមានកំណត់ក្នុង យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ តាមរយៈការជំរុញការកសាងកម្ពុជាឲ្យក្លាយជាតួអង្គដ៏លេចធ្លោមួយក្នុងតំបន់ ដែលមានភាពប្រកួតប្រជែងខ្ពស់, មានមូលដ្ឋានសេដ្ឋកិច្ចចម្រុះ និង រឹងមាំ គាំទ្រដោយទំនើបកម្ម, ទេពកោសល្យជំនាញ និង ការប្តេជ្ញាចិត្ត ចំពោះចីរភាពបរិស្ថាន; ព្រមទាំង មានភាពស្វាហាប់ និង ភាពធន់ទៅនឹងភាពមិនប្រាកដប្រជាសកល, ទាំងបច្ចុប្បន្ន និង អនាគត; ដើម្បីធានាឲ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព, បរិយាបន្ន, សុខុមាលភាព និង វិបុលភាព សម្រាប់ប្រជាជនកម្ពុជា»** ។

**កម្មវិធី** នេះ បានដាក់ចេញនូវកញ្ចប់វិធានការ ដែលមានលក្ខណៈច្បាស់លាស់ និង ជាក់ស្តែងនិយម ដែលអាចអនុវត្តបាន ប្រកបដោយប្រសិទ្ធភាព ដោយចែកចេញជា **៣ សសរស្តម្ភ** ដូចខាងក្រោម៖

**ទី១. កម្មវិធីគាំទ្រសេដ្ឋកិច្ចតាមវិស័យ ក្នុងរយៈពេលខ្លី ទៅមធ្យម** ដោយមានការដាក់ចេញ នូវវិធានការគោលនយោបាយមុតស្រួច និង ចំគោលដៅ, ទាំងវិធានការ ដែលរាជរដ្ឋាភិបាល បានដាក់ចេញកន្លងមក និង វិធានការថ្មី, ដើម្បីគាំពារកំណើនសេដ្ឋកិច្ច, ជាពិសេស ក្នុងវិស័យដែលត្រូវបានរំពឹងទុកថា នឹងមានកំណើនយឺត, ដោយដោះស្រាយបញ្ហានៃការរាំងស្ទះខ្សែច្រវាក់ផលិតកម្ម, កាត់បន្ថយថ្លៃដើមផលិតកម្ម, ព្រមទាំង រក្សា

ឲ្យបាននូវលំនឹងជីវភាពរបស់ប្រជាជន និង គាំទ្រដល់ការចាយវាយ របស់ប្រជាជនទូទៅ ។ ជាក់ស្តែង, ស្របតាមការកំណត់ក្នុង **កម្មវិធី** នេះ, រាជរដ្ឋាភិបាល បានសម្រេចផ្តល់ការ-លើកលែង, អនុគ្រោះ និង ពន្យារពេលអនុវត្តពន្ធ ក្នុងវិស័យគន្លឹះមួយចំនួន ដូចជា វិស័យកសិកម្ម, ទេសចរណ៍, សំណង់ និង អចលទ្រព្យ, អប់រំ, អាកាសចរណ៍, និង សិល្បៈ និង ភាពយន្តខ្មែរ ជាដើម ។

**ទី២. កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ៖** ដូចត្រូវបានគូសបញ្ជាក់, ក្នុងរបាយការណ៍របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ផាន់ ផល្លា**, កាលពីចុងឆ្នាំ ២០២៣, ក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩, **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** បានប្រគល់ភារកិច្ចឲ្យគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំ **កម្មវិធី** នេះឡើង ដើម្បីដោះស្រាយឲ្យបាន, ក្នុងនីតិកាលទី ៧ នេះ នៃរដ្ឋសភា, នូវបញ្ហាប្រឈមចម្បងៗ របស់វិស័យឯកជន ដូចជា៖ ការបង្កើនតម្លៃបន្ថែមនៃចន្ទល់សេដ្ឋកិច្ចដែលមានស្រាប់, និង ការជំរុញ និង ការគាំទ្រការ-អភិវឌ្ឍចន្ទល់សេដ្ឋកិច្ចដែលកំពុងផុសឡើង និង មានសក្តានុពលខ្ពស់; ការលើកកម្ពស់បរិយាកាសសម្រាប់ធុរកិច្ច និង ការវិនិយោគ; ការជំរុញការផលិត និង ការប្រើប្រាស់ផលិតផលក្នុងស្រុក; ការអភិវឌ្ឍជំនាញ និង ការពង្រឹងគុណភាពនៃការអប់រំ; ការគាំទ្រដល់ពលករទេសន្តប្រវេសន៍ ពីប្រទេសជិតខាង; ការអភិវឌ្ឍសហគ្រាសធុនមីក្រូ, តូច និង មធ្យម; ការលើកកម្ពស់កិច្ចគាំពារសង្គម និង ការធានាចីរភាពបរិស្ថាន; ព្រមទាំង ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស និង តំបន់ឧស្សាហកម្មសមាហរណ និង ការអភិវឌ្ឍប៉ូលសេដ្ឋកិច្ចសំខាន់ៗ រួមមាន៖ បណ្តាខេត្តនៅភូមិភាគពាយ័ព្យ ព្រមទាំង ខេត្តបាត់ដំបង, ពោធិ៍សាត់, បន្ទាយមានជ័យ, ប៉ៃលិន និង សៀមរាប ។

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមជម្រាបជូនអង្គពិធីថា ក្នុង **កម្មវិធី** នេះ, **«ការកែលម្អបរិយាកាសសម្រាប់ធុរកិច្ច និង ការវិនិយោគនៅកម្ពុជា»** ក៏ត្រូវបានកំណត់ជាអាទិភាពចម្បងមួយ, ដោយរាជរដ្ឋាភិបាល បានសម្រេចបង្កើតក្រុមការងារអន្តរក្រសួង ក្រោមការសម្របសម្រួល និង ការដឹកនាំ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគោល-នយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាជិកប្រមាណ ១០០ រូប មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ៣០ ។ ក្រុមការងារនេះ មានតួនាទីកំណត់បញ្ហាប្រឈម,

ដាក់ចេញនូវវិធានការឆ្លើយតប និង ជំរុញការអនុវត្ត ដោយប្រើប្រាស់ «**សន្ទស្សន៍នៃការវាយតម្លៃលើភាពរួចរាល់នៃធុរកិច្ច** (Business Ready ឬ B-READY)» ជាមូលដ្ឋាន ដើម្បីបង្កើតបរិយាកាសអំណោយផល ដល់ការធ្វើធុរកិច្ច និង ការវិនិយោគនៅកម្ពុជា ឲ្យបានជាអតិបរមា ក្នុងទិសដៅជំរុញការអភិវឌ្ឍវិស័យឯកជន និង ពង្រឹងភាពប្រកួតប្រជែង ព្រមទាំង លើកកម្ពស់ភាពទាក់ទាញរបស់កម្ពុជា និង ភាពជឿទុកចិត្តលើកម្ពុជា ពីសំណាក់ទីផ្សារ ជាតិ និង អន្តរជាតិ ។ ក្រុមការងារនេះ បានរៀបចំ «**កម្មវិធីជំរុញការកែលម្អបរិយាកាសសម្រាប់ធុរកិច្ច និង ការវិនិយោគនៅកម្ពុជា ឆ្នាំ ២០២៥-២០២៨**» ដែលរាជរដ្ឋាភិបាល បានអនុម័ត កាលថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២៥ និង ដែលនឹងត្រូវបានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នាថ្ងៃនេះ ផងដែរ ។

ខ្ញុំសូមជម្រាបជូនអង្គពិធីបន្ថែមថា, ស្របតាម **កម្មវិធី** ដែលត្រូវបានដាក់ឲ្យអនុវត្ត ជាផ្លូវការ នាថ្ងៃនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងដាក់ចេញនូវកញ្ចប់វិធានការមុតស្រួច ក្រោមសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ដើម្បីពង្រឹងប្រសិទ្ធភាព, អភិបាលកិច្ច, តម្លាភាព និង គណនេយ្យភាព នៃកិច្ចប្រតិបត្តិការរបស់ស្ថាប័នដ៏មានសារៈសំខាន់នេះ ក្នុងពេលដ៏ឆាប់ខាងមុខ ផងដែរ ។

**ទី៣. កម្មវិធីសម្របខ្លួនទៅនឹងការប្រែប្រួលរបបពាណិជ្ជកម្មអន្តរជាតិ** ដើម្បីត្រៀមខ្លួនឲ្យបានរួចរាល់ ក្នុងការឆ្លើយតប ប្រកបដោយភាពបុរេសកម្ម សំដៅចាប់យកកាលានុវត្តភាពថ្មី, ជាពិសេស ក្នុងបរិការណ៍ដែលកម្ពុជាកំពុងត្រៀមខ្លួនចាកចេញពីចំណាត់ថ្នាក់នៃក្រុមប្រទេសអភិវឌ្ឍតិចតួច នៅឆ្នាំ ២០២៩ ។ ក្នុងនោះ, រាជរដ្ឋាភិបាល នឹងផ្តោតលើការបន្តជំរុញការប្រើប្រាស់ប្រព័ន្ធអនុគ្រោះនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលមានស្រាប់ ឲ្យអស់លទ្ធភាព, លើកកម្ពស់ការទុកចិត្តលើការនាំចេញពីកម្ពុជា, ជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញ, ត្រៀម និង សម្របខ្លួន ក្នុងការទទួលយក និង អនុវត្តបទប្បញ្ញត្តិ ដែលមានស្តង់ដា និង កាតព្វកិច្ចខ្ពស់ជាងមុន, ពង្រឹងស្ថិរភាព និង ភាពធន់ ព្រមទាំង ជំរុញភាពស៊ីជម្រៅនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, និង បន្តជំរុញការអភិវឌ្ឍបច្ចេកវិទ្យា និង នវានុវត្តន៍ ។

***ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!***

ការប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ «**កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា**» នាឱកាសនេះ គឺជាការចាប់ផ្តើមប្រមូលផ្តុំ នូវការយកចិត្តទុកដាក់ និង ការជំរុញការអនុវត្ត នូវវិធានការទាំងអស់ ឲ្យមានប្រសិទ្ធភាពខ្ពស់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។ ក្នុងស្មារតីនេះ, ខ្ញុំសូមស្នើឲ្យអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្របសម្រួល និង ជំរុញការអនុវត្ត **កម្មវិធី** នេះ ឲ្យបានល្អ; រៀបចំយន្តការតាមដាន, ត្រួតពិនិត្យ និង វាយតម្លៃ ជាប់ជាប្រចាំ; និង ពិនិត្យ និង លើកសំណូមពរកែសម្រួលវិធានការនានា តាមការចាំបាច់; ដើម្បីធានាប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពនៃការអនុវត្ត ។ ទន្ទឹមនេះ, ខ្ញុំក៏សូមជំរុញ និង លើកទឹកចិត្តក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ អនុវត្តផែនការសកម្មភាព តាមដែនសមត្ថកិច្ចរៀងខ្លួន ដោយយកចិត្តទុកដាក់ និង ប្រកបដោយការទទួលខុសត្រូវខ្ពស់ ព្រមទាំង ផ្តល់កិច្ចសហការស្អិតល្មួត ជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការផ្តល់របាយការណ៍វឌ្ឍនភាព និង ក្នុងការរៀបចំយន្តការតាមដាន, ត្រួតពិនិត្យ និង វាយតម្លៃ, ក៏ដូចជា ក្នុងការពិនិត្យលើកយោបល់ ស្នើសុំកែសម្រួល **កម្មវិធី** នេះ តាមការចាំបាច់ជាក់ស្តែង ។ ជាមួយគ្នា, ខ្ញុំក៏សូមលើកទឹកចិត្តដៃគូអភិវឌ្ឍ និង ស្ថាប័នជាតិ និង អន្តរជាតិពាក់ព័ន្ធទាំងឡាយ, រួមបញ្ចូលទាំងវិស័យឯកជនផង, បន្តចូលរួមជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល ក្នុងការជំរុញការអនុវត្ត **កម្មវិធី** ដ៏មានសារៈសំខាន់នេះ សំដៅសម្រេចបានលទ្ធផលដ៏ត្រចះត្រចង់ តាមការរំពឹងទុក ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គពិធី** បានសមប្រកបដោយសុខភាពល្អបរិបូរណ៍, សម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច, ព្រមទាំង ទទួលបាននូវវិបុលភាព និង សុភមង្គល ក្នុងក្រុមគ្រួសាររៀងខ្លួន ។

តាងនាម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, ខ្ញុំមានកិត្តិយស សូមប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ «**កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីជំរុញកំណើន**

**សេដ្ឋកិច្ច ក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា»** និង **«កម្មវិធីជំរុញការកែលម្អបរិយាកាសសម្រាប់ធុរកិច្ច និងការវិនិយោគនៅកម្ពុជា ឆ្នាំ ២០២៥-២០២៨»** ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ!***